ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខៈ ២១៦ ......កប/ប្រ.ក

លិខិតចូល

ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៧

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍

+++

## រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០១០០/០០៧ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០០ ស្តីពីការបង្កើត អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បកចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-យោងលិខិតលេខ ១៦២ ក.ក.ប.រ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីករណីសុំចាត់បញ្ជូនសមាជិក - សមាជិកាក្រុមប្រឹក្សានយោបាយ ០១រូប និងក្រុមប្រឹក្សាបច្ចេកទេសមេរោគអេដស៍/ជំងឺអេដស៍ ០១រូប របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ស ម្រេ ច

**ប្រការ ១.-**

បង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ដែលមានអក្សរកាត់ថា **គ.ប.ជ.អ** ដើម្បីបំរើឱ្យផលប្រយោជន៍ការងារអេដស៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**ប្រការ ២.-**

**គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ច ÷**

១.ជាជំនួយការឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីសិក្សាស្រាវជ្រាវ បង្កើតផែនការយុទ្ធសាស្ត្រ ផែនការការងារ និងអនុវត្តនូវផែនការសកម្មភាពកម្មវិធីអេដស៍ដល់ កម្មករ និយោជិត និយោជក ពលករទេសន្តរប្រវេសន៍តាមសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ជនចំណាកស្រុក និងបុគ្គលិកមន្ត្រីរាជការស្ថិតនៅក្រោមឱវាទក្រសួង ។

២.ចូលរួមសហការសម្របសម្រួលជាមួយអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីស្វែងរកប្រភពធនធាន ថវិកា សម្ភារៈ បច្ចេកទេសពីអង្គការជាតិ អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តផែនការសកម្មភាពឱ្យបានជោគជ័យ ។

៣. អប់រំផ្សព្វផ្សាយដល់ពលករចល័តទាំងក្នុង និងក្រៅប្រទេស មុនពេលចាកចេញ និងពេលត្រឡប់មកវិញដើម្បីទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ជាពិសេសពលករដែលបានទៅបំពេញការងារនៅក្រៅប្រទេស ។

៤. បង្កើនការចូលរួមយ៉ាងសកម្ម របស់អ្នកផ្ទុកមេរោគអេដស៍ និងអ្នករងផលប៉ះពាល់ ដោយសារជំងឺអេដស៍ ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់កម្មករ និយោជិតនៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន ។

៥. ផ្តល់ការគាំទ្រដល់ស្ត្រី/កុមារ ទាំងផ្នែកសំភារៈ ស្មារតី និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាពិសេសស្ត្រី/កុមារដែលផ្ទុកមេរោគអេដស៍ ឬអ្នកទទួលរងផលប៉ះពាល់ដោយសារមេរោគអេដស៍/ជំងឺអេដស៍ ។

៦.ត្រួតពិនិត្យ និងវាយតំលៃលើលទ្ធផលអនុវត្តគោលនយោបាយ គោលការណ៍ ផែនការកម្មវិធីបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ និងបូកសរុបលទ្ធផលការងារអេដស៍ប្រចាំឆ្នាំ ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**ប្រការ ៣.-**

**សមាសភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ មានដូចតទៅ÷**

| | | | |
|---|---|---|---|
| ១.លោកជំទាវ | **ឡូរ៉ាត់ ចន្ថា** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២. ឯកឧត្តម | **អ៊ុំ មាន** | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣.ឯកឧត្តម | **សូ សាមុត** | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៤. លោកវេជ្ជ. | **ឈឹម យុទ្ធសំគី** | អនុប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិកអចិន្ត្រៃយ៍ |
| ៥. លោក | **សាលី មុនី** | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | សមាជិក |
| ៦. លោកស្រី | **ជា សុខនី** | អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម | សមាជិក |
| ៧. លោក | **គីម ធីមិត្ត** | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៨.លោក | **គាម ម៉ារិន្ទ័យ៉ា** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៩. លោក | **ជុំ មុំ** | អនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ១០ លោក | **តូច ទុន្នី** | អនុប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ១១. លោក | **ជួប ណារ៉ាត់** | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម | សមាជិក |
| ១២. លោក | **សួន ស៊ីឡេង** | អនុប្រធាននាយកដ្ឋានសន្តិសុខសង្គម | សមាជិក |
| ១៣. លោកស្រី | **នុច សុភាព** | អនុប្រធាននាយកដ្ឋានការងារកុមារ | សមាជិក |
| ១៤. លោកស្រី | **នាង សុខរ៉ាស៊ី** | អនុប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិក |
| ១៥. លោក | **ហ៊ុង ស៊ីដេត** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | សមាជិក |

១៦. លោក **គួន តីម៉ារ៉ែឡេន** អនុប្រធាននាយកដ្ឋានស្តង់ដារជាតិសមត្ថភាព សមាជិក

១៧. លោក **គង់ ចំន្ទតារា** អនុប្រធាននាយកដ្ឋានព័ត៌មានទីផ្សារការងារ សមាជិក

១៨. លោកស្រី **ម៉ៅ ធីតា** អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង សមាជិក

១៩. លោក **យី ភន្និដ្ឋា** អនុប្រធាននាយកដ្ឋានពេទ្យការងារ សមាជិក

**ប្រការ ៤.-**

គណៈកម្មាធិការនេះមានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៅនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលអាចសហការសម្របសម្រួល ដោះស្រាយរាល់បញ្ហាមេរោគអេដស៍/ជំងឺអេដស៍ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបំពេញការងាររបស់ខ្លួន ។

**ប្រការ ៥.-**

គណៈកម្មាធិការនេះ អាចលើកសំណើជូនថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការជ្រើសរើសសមាជិកបន្ថែមទៀត ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនក្នុងករណីចាំបាច់ ។

**ប្រការ ៦.-**

ប្រកាសលេខ ០២ក.ក.ប.វ/ប្រ.ក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ ២០០៦ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគ្រប់អង្គភាពស្ថិតក្រោមឱវាទក្រសួង ស្ថាប័នពាក់ព័ន្ធ និងលោក លោកស្រី ដូចមានចែងក្នុងប្រការ៣ មានភារកិច្ចរៀងៗខ្លួនអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៧

រដ្ឋមន្ត្រី

**វង សូត**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាក់ព័ន្ធ
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- អង្គការក្រៅរដ្ឋាភិបាល
- ក្រុមហ៊ុនពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៧
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ